វិទ្យាស្ថានសភាកម្ពុជា

PARLIAMENTARY INSTITUTE OF CAMBODIA

## ឯកសារស្រាវជ្រាវ

### នាយកដ្ឋានព័ត៌មាននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃ
### ព្រះរាជាណាចក្រកម្ពុជា

# ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ
# របស់សភា៖ ករណីសិក្សាទៅលើ សភាសាធារណៈ
# រដ្ឋកូរ៉េ អូស្ត្រាលី និងស៊ុយអ៊ែត

ខែកក្កដា ឆ្នាំ២០១៧


អ្នកស្រាវជ្រាវ៖ **លោក នន់ អស្សាច័ន្ទ**

អ្នកបណ្ដុះបណ្ដាល៖ **លោកស្រី រស់ បណ្ដែត**

## កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយ ដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជាសភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះ មានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជា
ឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

© រក្សាសិទ្ធិ ឆ្នាំ ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា

១. សេចក្តីផ្តើម ........ 1
២. វិធីសាស្រ្តប្រើប្រាស់សម្រាប់កិច្ចការព័ត៌មាន និងទំនាក់ទំនងសាធារណៈរបស់សភា ........ 1
៣. បញ្ហាប្រឈមទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មានសភា និងកិច្ចទំនាក់ទំនងសធារណៈ ........ 2
៤.ករណីសិក្សា ........ 3
៤.១. សាធារណៈរដ្ឋកូរ៉េ ........ 3
៤.១.១ អង្គភាព និងឧបករណ៍ប្រើប្រាស់ក្នុងកិច្ចទំនាក់ទំនងសាធារណៈ ........ 4
៤.១.២ បទពិសោធន៍ល្អៗ ........ 5
៤.២ អូស្រ្តាលី ........ 5
៤.២.១ អង្គភាព និងឧបករណ៍ប្រើប្រាស់ក្នុងកិច្ចទំនាក់ទំនងសាធារណៈ ........ 6
៤.២.២ បទពិសោធន៍ល្អៗ ........ 7
៤.៣ ស៊ុយអ៊ែត ........ 8
៤.៣.១ អង្គភាព និងឧបករណ៍ប្រើប្រាស់ក្នុងកិច្ចទំនាក់ទំនងសាធារណៈ ........ 8
៤.៣.២ បទពិសោធន៍ល្អៗ ........ 9
៥. សេចក្តីសន្និដ្ឋាន ........ 9
ឯកសារយោង ........ 11

## ១. សេចក្តីផ្តើម

នៅក្នុងប្រទេសប្រជាធិបតេយ្យ សភាត្រូវមានតម្លាភាពនិងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ សភាត្រូវផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណៈជន ទាក់ទងនឹងការងាររបស់សភា ហើយទន្ទឹមគ្នានេះដែរ ត្រូវអនុញ្ញាតឲ្យប្រជាពលរដ្ឋបញ្ចេញមតិយោបល់ចំពោះការងារទាំងឡាយរបស់សភា។ នីតិវិធីបែបនេះ នឹងជួយឲ្យមានការយល់ពីគ្នាទៅវិញទៅមក និងការចូលរួមរវាងសភានិងប្រជាពលរដ្ឋ។[1]

ព័ត៌មាន និងទំនាក់ទំនងសាធារណៈ គឺជាមធ្យោបាយសម្រាប់ឲ្យសមាជិកសភា ប្រើប្រាស់ដើម្បីយល់ និងរក្សាទំនាក់ទំនងជាមួយប្រជាពលរដ្ឋ។[2] ប្រទេសនីមួយៗ មានវិធីសាស្ត្ររៀងៗខ្លួនក្នុងការអនុវត្តការងារទំនាក់ទំនងសាធារណៈ ដោយផ្អែកលើកត្តាវប្បធម៌ ប្រព័ន្ធសេដ្ឋកិច្ច កម្រិតអភិវឌ្ឍន៍ និងស្ថានភាពនយោបាយ។[3] ការអនុវត្តការងាររបស់សភា ត្រូវបានវាយតម្លៃនៅក្នុងសន្ទស្សន៍សភាអេឡិកត្រូនិកពិភពលោក (World e-Parliament Index)។ នៅឆ្នាំ ២០១៦ កិច្ចការទំនាក់ទំនងសាធារណៈរបស់រដ្ឋសភាកម្ពុជាទទួលបានពិន្ទុ ៣២/១០០ និងព្រឹទ្ធសភាវិញទទួលបានពិន្ទុ ៣៦/១០០។[4] ពិន្ទុដែលទទួលបាននេះ អាចបញ្ជាក់ថាសភាកម្ពុជាកំពុងតែខិតខំប្រឹងប្រែងពង្រីកកិច្ចការទំនាក់ទំនងសាធារណៈជាមួយប្រជាពលរដ្ឋ។ ការសិក្សាពីនីតិវិធីទំនាក់ទំនងសាធាណៈនៃបណ្តាប្រទេសដទៃទៀត ប្រហែលជាអាចផ្តល់នូវចំណេះដឹងល្អៗសម្រាប់សភាកម្ពុជា។

ឯកសារស្រាវជ្រាវនេះ នឹងត្រូវសរសេរឡើងដោយការមានការសិក្សាស្វែងយល់ពីបទពិសោធន៍ប្រទេសមួយចំនួន ដូចជា សាធារណៈរដ្ឋកូរ៉េ អូស្ត្រាលី និងស៊ុយអ៊ែត ដើម្បីជាចំណេះដឹងសម្រាប់សភាកម្ពុជា ក៏ដូចជាការជួយឲ្យមានការអភិវឌ្ឍបន្ថែមទៅដល់ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងសាធារណៈទាំងពេលបច្ចុប្បន្ន និងអនាគត។ ឯកសារស្រាវជ្រាវនេះផ្តោតសំខាន់៖ ទី១/វិធីសាស្ត្រទូទៅដែលប្រើប្រាស់សម្រាប់ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈរបស់សភា ទី២/បញ្ហាប្រឈមដែលកើតឡើងជាញឹកញាប់ ទាក់ទងនឹងការអនុវត្តការងារទំនាក់ទំនងសាធារណៈរបស់សភា និងចុងក្រោយពាក់ព័ន្ធនឹងបទពិសោធន៍ល្អៗក្នុងការងារទំនាក់ទំនងសាធារណៈរបស់សភាសាធាណៈរដ្ឋកូរ៉េ អូស្ត្រាលី និងស៊ុយអ៊ែតដោយផ្តោតសំខាន់ទៅលើតួនាទី ការទទួលខុសត្រូវរបស់នាយកដ្ឋានពាក់ព័ន្ធ និងឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់កិច្ចការទំនាក់ទំនងសាធារណៈ ។

## ២. វិធីសាស្ត្រប្រើប្រាស់សម្រាប់កិច្ចការព័ត៌មាន និងទំនាក់ទំនងសាធារណៈរបស់សភា

គ្រប់ស្ថាប័នទាំងអស់ សុទ្ធតែប្រើប្រាស់ទំនាក់ទំនងសាធារណៈដើម្បីបង្ហាញពីសកម្មភាពជំនាញរបស់ខ្លួនទៅកាន់សាធារណៈ។ ជាពិសេស សភាបានចាប់យកវិធីសាស្ត្រថ្មីៗ បន្ថែមទៅវិធី

សាស្ត្រដែលធ្លាប់បានប្រើប្រាស់ក្នុងកិច្ចការទំនាក់ទំនងសាធារណៈរួមមានដូចជា ការចេញផ្សាយកិច្ចពិភាក្សាសមាជិកសភា របាយការណ៍ កិច្ចទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ[5] និងសកម្មភាពផ្សេងៗក្រៅស្ថាប័ន។

កិច្ចទំនាក់ទំនងសាធារណៈ មានភាពរីកចម្រើនជាមួយនឹងការរីកដុះដាលនៃការប្រើប្រាស់ប្រព័ន្ធ ទំនាក់ទំនង និងបច្ចេកវិទ្យាព័ត៌មាន (ICTs)។ ៧៤ ភាគរយនៃសភាទាំងអស់ដែលជាសមាជិកសហភាពអន្តរសភា (IPU) មានមតិយល់ស្របចំពោះសារៈសំខាន់ និងអត្ថប្រយោជន៍របស់ការប្រើប្រាស់ឧបករណ៍ឌីជីថល មានដូចជាគេហទំព័រ អ៊ីម៉ែល និងប្រព័ន្ធផ្សព្វផ្សាយសង្គម (social media)។ ឧបករណ៍ទាំងនេះ ជួយឲ្យប្រជាពលរដ្ឋទទួលបានព័ត៌មានពីដំណើរការការអនុម័តច្បាប់ បញ្ហាទាក់ទងនឹងគោលនយោបាយ និងជួយឲ្យប្រជាជនកាន់តែឈានជើងចូលក្នុងកិច្ចការនយោបាយកាន់តែច្រើន។[6] នៅក្នុងឆ្នាំ ២០១២ ព័ត៌មានដែលត្រូវបានផ្សព្វផ្សាយដោយការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន មានរហូតដល់ ៨៩ ភាគរយ ដែលគឺជាព័ត៌មាន និងឯកសារផ្សេងៗរបស់សភាជាសមាជិកសហភាពអន្តរសភា (IPU)។ ប៉ុន្តែ ក្នុងចំណោមប្រទេសដែលមានប្រាក់ចំណូលទាបទាំងអស់ មានតែ ២៥ ភាគរយប៉ុណ្ណោះដែលបានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ទំនាក់ទំនងជាមួយយុវជន។[6]

## ៣. បញ្ហាប្រឈមទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មានសភា និងកិច្ចទំនាក់ទំនងសាធារណៈ

សមាជិកសហភាពអន្តរសភាយល់ពីសារៈសំខាន់ក្នុងចែករំលែកព័ត៌មាន និងគ្រប់គ្រងផ្សព្វផ្សាយសកម្មភាពផ្សេងៗរបស់សភា។[7] ការបង្កើតឲ្យមានទំនាក់ទំនងផ្ទាល់រវាងប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយគឺជាកត្តាចាំបាច់សម្រាប់លុបបំបាត់នូវគម្លាតរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ[7]។ ទោះបីយ៉ាងនេះក្តី វិធីសាស្ត្រសម្រាប់កិច្ចទំនាក់ទំនងសាធារណៈរបស់ប្រទេសមួយចំនួនមិនទាន់ត្រូវបានអនុវត្តល្អនៅឡើយ។

សហភាពអន្តរសភាបានរកឃើញថា ព័ត៌មានសភាមិនមានភាពទាក់ទាញចំពោះប៉ុស្តិ៍ទូរទស្សន៍ដែលកំពុងប្រកបអាជីវកម្មឡើយ។ ប៉ុស្តិ៍ទូរទស្សន៍ទាំងនេះ ព្យាយាមទាក់ទាញចំណាប់អារម្មណ៍របស់ទស្សនិកជន ដោយការបញ្ចាំងនូវផ្ទាំងទស្សនីភាពដែលជាតម្រូវភាគច្រើនរបស់ពួកគេ ដែលធ្វើឲ្យព័ត៌មានទាំងឡាយទាក់ទងនឹងសភាមិនសូវមានការពេញនិយម។ កត្តានេះ ផ្តល់នូវផលវិបាកសម្រាប់សមាជិកសភា ក្នុងការបញ្ជូនព័ត៌មានទៅកាន់សាធារណៈ។[7]

ឧទាហរណ៍ដ៏គួរឲ្យចាប់អារម្មណ៍មួយ គឺការផ្សព្វផ្សាយតាមទូរទស្សន៍នៅទ្វីបអាហ្វ្រិក។ ប្រជាជនអាហ្វ្រិកភាគច្រើនមានជីវភាពក្រីក្រ រស់នៅឯជនបទដែលគ្មានអគ្គិសនីគ្រប់គ្រាន់ និងពុំមានលទ្ធ

ភាពទិញទូរទស្សន៍។ ដូច្នេះ សកម្មភាពទាំងឡាយរបស់សភាមិនអាចផ្សព្វផ្សាយទៅប្រជាជននៅជនបទតាមទូរទស្សន៍ឡើយ។[7]

នៅទ្វីបអាហ្វ្រិក (លើកលែងតែប្រទេសអាហ្វ្រិកខាងត្បូង) កិច្ចទំនាក់ទំនងសាធារណៈជួបប្រទះនូវបញ្ហាមួយចំនួន។ ទី១ កិច្ចទំនាក់ទំនងសាធារណៈ មិនសូវមានអ្នកយល់ដឹងច្រើន ដូច្នេះស្ថាប័ន អង្គភាពជាច្រើន ពុំសូវមានការយកចិត្តទុកដាក់ចំពោះទំនាក់ទំនងសាធារណៈ។ ទី២ មិនសូវមានអ្នកជំនាញក្នុងការងារទំនាក់ទំនងសាធារណៈ ដោយសារកត្តាប្រាក់ចំណូលដែលធ្វើឲ្យពួកគេងាកចេញពីការងារនេះដោយមិនខ្វល់ពីតម្លៃរបស់ការងារនេះ។ ទី៣ ប្រទេសជាច្រើននៅអាហ្វ្រិកសុទ្ធតែនិយាយច្រើនភាសា ដែលធ្វើឲ្យមានការលំបាកក្នុងការផ្សព្វផ្សាយព័ត៌មាន។ ទី៤ ការយល់ពីរបៀបប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតនៅឡើយ សម្រាប់ប្រទេសជាច្រើននៅអាហ្វ្រិក។ ចុងក្រោយហេដ្ឋារចនាសម្ព័ន្ធនៅមិនទាន់គ្រប់គ្រាន់ និងបណ្ដាលឲ្យមានបញ្ហាជាច្រើនដូចជាគ្មានផ្លូវសម្រាប់ទៅកាន់តំបន់គោលដៅ។[8]

របាយការណ៍សហភាពអន្តរសភាឆ្នាំ ២០១២ បានបង្ហាញថា សភានៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប មិនមានធនធានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តតាមប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ ភាពទន់ខ្សោយនេះ ត្រូវបានរាយការណ៍ថាបានកើតឡើង ៤ឆ្នាំជាប់គ្នារហូតដល់ឆ្នាំ ២០១៦ ដោយសហភាពអន្តរសភា។ ជាងនេះទៀត សភាទាំងអស់ត្រូវដោះស្រាយបញ្ហាទាក់ទងនឹងចំណេះដឹង សមត្ថភាពរបស់បុគ្គលិក និងសមាជិកសភា បើទោះបីថាថវិការបស់ពួកគេមានកម្រិត។[6] របាយការណ៍នេះក៏បានបង្ហាញពីបញ្ហាមួយចំនួនទាក់ទងនឹងការទាញយកបច្ចេកវិទ្យាមកប្រើប្រាស់ កង្វះភាពជាអ្នកដឹកនាំ និងការតម្រង់ទិសសភាដែលទាមទារឲ្យមានការដោះស្រាយជាលក្ខណៈប្រព័ន្ធ។[6]

## ៤.ករណីសិក្សា

### *៤.១. សាធារណៈរដ្ឋកូរ៉េ*

អាណានិគមជប៉ុនទៅលើកូរ៉េខាងត្បូងបានបញ្ចប់ជាមួយនឹងការផុតរលត់សង្គ្រាមលោកលើកទី ២ នៅក្នុងឆ្នាំ ១៩៤៥។ រដ្ឋសភាសាធារណរដ្ឋកូរ៉េត្រូវបានបង្កើតនៅឆ្នាំ ១៩៤៨ ដោយមានសមាជិក ១៩៨ រូប។ រដ្ឋធម្មនុញ្ញរបស់ប្រទេសនេះ បានកំណត់ឲ្យមានសភាមួយថ្នាក់ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបែបប្រធានាធិបតី។ លេខាធិការដ្ឋានរដ្ឋសភាមានកាតព្វកិច្ចគ្រប់គ្រងសកម្មភាពការងារទាំងអស់របស់សភា មានដូចជា កិច្ចប្រជុំ ការចេញផ្សាយពីដំណើរការការអនុម័តច្បាប់ ការចាត់ចែងថវិកា ការពិនិត្យការងាររបស់ស្ថាប័ននីតិប្រតិបត្តិ ការដោះស្រាយពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋ និងការជួយជ្រុមជ្រែងការងារទាក់ទងនឹងដំណើរការការអនុម័តច្បាប់ និងសកម្មភាពផ្សេងៗ។ ជាងនេះ

ទៀត សភានេះក៏មានការិយាល័យថវិកាសភា (Budget Office) ការិយាល័យសេវាស្រាវជ្រាវ និងបណ្ណាល័យដែលផ្តល់សេវាទៅឲ្យសភា និងសាធារណៈជន។[9]

ដើម្បីជួយឲ្យប្រជាជនកាន់តែមានការយល់ដឹងពីសភា និងអាចឲ្យពួកគេចូលរួមមតិយោបល់នៅក្នុងសភា រដ្ឋសភាសាធារណៈរដ្ឋកូរ៉េបានបង្កើតអង្គភាពមួយចំនួនដែលទទួលខុសត្រូវការងារទាក់ទងនឹងទំនាក់ទំនងសាធារណៈ។ ខាងក្រោមនេះ គឺជាអង្គភាពដែលទទួលបន្ទុកកិច្ចការទំនាក់ទំនងសាធារណៈ និងបទពិសោធន៍ល្អៗដែលពួកគេបានអនុវត្ត។

## ៤.១.១ អង្គភាព និងឧបករណ៍ប្រើប្រាស់ក្នុងកិច្ចទំនាក់ទំនងសាធារណៈ

អង្គភាពមួយចំនួនដែលទទួលខុសត្រូវក្នុងកិច្ចការទំនាក់ទំនងសាធារណៈមានដូចជា អគ្គនាយកផែនការទំនាក់ទំនងទំនងសាធារណៈ (Director General of Public Relations Planning Office) ការិយាល័យទូរទស្សន៍សភា (National Assembly TV) ការិយាល័យព័ត៌មានសភា (Parliamentary Information Office) និងការិយាល័យសេវាព័ត៌មាន ( Information Services Bureau).[10] អង្គភាពទាំងនេះប្រើប្រាស់ឧបករណ៍ និងមធ្យោបាយមានដូចជា៖

- សភាបានបង្កើតប៉ុស្តិ៍ទូរទស្សន៍ផ្ទាល់ខ្លួន ដែលមានឈ្មោះថាស្ថានីយ៍ផ្សព្វផ្សាយព័ត៌មានសភា (National Assembly Broadcasting Station/ NATV). ស្ថានីយ៍នេះផ្តល់ព័ត៌មាន ២៤ ម៉ោងក្នុង ១ថ្ងៃ និងបន្តផ្ទាល់ព្រឹត្តិការណ៍ផ្សេងៗ។ ស្ថានីយ៍នេះត្រូវបង្កើតកាលពីឆ្នាំ ២០០៤ មានគោលការណ៍អព្យាក្រឹត្យ និងផ្សាយបន្តផ្ទាល់កិច្ចប្រជុំពេញអង្គ កិច្ចប្រជុំគណៈកម្មការ និង កិច្ចប្រជុំផ្សេងៗ។ ប៉ុស្តិ៍ទូរទស្សន៍នេះ ផ្តល់ព័ត៌មានទាក់ទងនឹងដំណើរការការអនុម័តច្បាប់ ក៏ដូចជាបញ្ហាផ្សេងៗ។ លើសពីនេះទៀត ប្រជាជនក៏អាចមើលប៉ុស្តិ៍នេះ តាមអ៊ីនធឺណែតបានដែរ។[9]
- សមាជិកសភាអាចទាញយកអត្ថប្រយោជន៍ពីការរីកចម្រើននៃការប្រើប្រាស់ទូរស័ព្ទឆ្លាត (smart phone) និងអ៊ីនធឺណែតទៅលើសកម្មភាពនៅក្រៅស្ថាប័ន និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការការអនុម័តច្បាប់។[11] ឧទាហរណ៍មានផែនការជាច្រើនទាក់ទងនឹងការបង្កើតកម្មវិធីទូរស័ព្ទពិនិត្យមើលដំណើរការធ្វើច្បាប់ (Legislative App) ដែលនឹងជួយឲ្យសមាជិកសភាស្តាប់មតិសាធារណៈដែលផ្ញើមកតាមកម្មវិធីនេះ។ កម្មវិធីនេះគឺឧបករណ៍ថតសំឡេងដែលអាចបញ្ជូនសំឡេងរបស់ប្រជាពលរដ្ឋមកកាន់សភា។ [12]
- ជាងនេះទៀត នៅមានកម្មវិធីទូរស័ព្ទជាច្រើនទៀត រួមនឹងគេហទំព័រដែលអាចប្រើប្រាស់តាមទូរស័ព្ទ (http://m.na.go.kr) និងអាចឲ្យអ្នកប្រើប្រាស់ភ្ជាប់ទំនាក់ទំនង និងទាញយកព័ត៌មានជាច្រើន។ កម្មវិធីទូរស័ព្ទទាំងនេះមានដូចជា៖ កម្មវិធីរួមបញ្ចូលគ្នាសម្រាប់រដ្ឋសភា (National Assembly integrated application) កម្មវិធីសម្រាប់ចែកចាយ

ព័ត៌មានស្ដីពីដំណើរការប្រព្រឹត្តិទៅរបស់សភា (application for distributing parliamentary proceedings) និងកម្មវិធីសម្រាប់តាមដានកិច្ចប្រជុំសភា (Assemblymen Square Application)។[9]

- មជ្ឈមណ្ឌលទស្សនាសភា (National Assembly Visitor Center) ផ្ដល់សេវាមគ្គុទ្ទេសក៍ ការពន្យល់ទៅដល់អ្នកមកទស្សនា នៅតាមសាលផ្សេងៗជាច្រើនរបស់សភា ដែលរួមមានទាំង សាលសម្រាប់បង្រៀនកុមារពីដំណើរការសភា។ គេហទំព័រ www.assembly.go.kr) ត្រូវប្រើប្រាស់សម្រាប់ចុះឈ្មោះចូលទស្សនាសភា និងមើលព័ត៌មានមួយចំនួន។[9]
- ជាចុងក្រោយ មានកម្មវិធីបណ្ដុះបណ្ដាលជាច្រើនស្ដីពីដំណើរការការអនុម័តច្បាប់ និងប្រព័ន្ធសភាដែលត្រូវរៀបចំឡើងសម្រាប់សមាជិកសភា បុគ្គលិក អ្នកអប់រំបណ្ដុះបណ្ដាល និងប្រជាពលរដ្ឋ។[13]

### ៤.១.២ បទពិសោធន៍ល្អៗ

តាមរយៈឧទាហរណ៍ទាំងនេះ យើងអាចមើលឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់សភាដើម្បីពង្រឹងទំនាក់ទំនងសាធារណៈនិងការយល់ដឹងជាសាធារណៈ។ ទីមួយ បច្ចេកវិទ្យាសម្រាប់សភាមានការរីកចម្រើននិងកាន់តែប្រសើរឡើង ជាពិសេសជាមួយនឹងការបង្កើតកម្មវិធីទូរស័ព្ទដែលត្រូវបានប្រើដើម្បីឲ្យប្រជាពលរដ្ឋបានដឹងពីសកម្មភាពរបស់សភា។ ទីពីរ ទូរទស្សន៍សភាផ្ដល់ព័ត៌មានភ្លាមៗដល់ប្រជាជនតាមតំបន់ផ្សេងៗ ស្របពេលជាមួយនឹងសកម្មភាពសភាដែលកំពុងកើតឡើង។ ទីបី សភាមិនមែនជាកន្លែងសម្រាប់តែសមាជិកសភាទេ ប៉ុន្តែមានការបើកចំហសម្រាប់សាធារណជនផងដែរ។ សាធារណជនប្រើប្រាស់បណ្ណាល័យ និងទស្សនាសភា ហើយទទួលការពន្យល់ពីកិច្ចសភា។ មិនត្រឹមតែមនុស្សពេញវ័យប៉ុណ្ណោះទេ កុមារក៏ត្រូវបានពន្យល់ពីការងារសភាដែរ។ មានសាលមួយដែលមានឈ្មោះថា សាលសម្រាប់បង្រៀនកុមារ (Children's Education Hall)។

## *៤.២ អូស្ត្រាលី*

អូស្ត្រាលីជាប្រទេសមួយស្ថិតនៅក្នុង Commonwealth។ ប្រទេសនេះ មានសភាពីរថ្នាក់។ រដ្ឋសភាមានសមាជិក ១៥០ រូប និងបង្កើតរដ្ឋាភិបាល។[14] រដ្ឋសភាមានអាណត្តិ ៣ ឆ្នាំ និងការបោះឆ្នោតជ្រើសតំណាងរាស្ត្រត្រូវប្រព្រឹត្តិទៅមុនពេលបញ្ចប់អាណត្តិនីមួយៗ។ គណបក្សពលករអូស្ត្រាលី ជាគណបក្សសេរីរបស់អូស្ត្រាលី (the Australian Labor Party, the Liberal Party of Australia) និងគណបក្សជាតិរបស់អូស្ត្រាលី (the National Party of Australia) គឺជាគណបក្សដែលមានសំឡេងភាគច្រើននៅក្នុងរដ្ឋសភាអូស្ត្រាលី។ បន្ថែមពីនេះទៀត ក៏មានគណបក្សតូចៗជាច្រើនទៀតកំពុងកើនឡើងនៅក្នុងសភា។[15]

ក្នុងកិច្ចទំនាក់ទំនងសាធារណៈ ការប្រើប្រាស់ពាក្យ "ការបង្កើនចំណេះដឹងសហគមន៍" (community awareness) ត្រូវចាត់ទុកថាជាសកម្មភាពដើម្បីជួយផ្សព្វផ្សាយពីដំណើរការរបស់សភា។ ប្រាក់ចំនួន ១.៣ លានដុល្លារត្រូវបានកំណត់ក្នុងគម្រោងឆ្នាំ ២០១៥-២០១៦ សម្រាប់សកម្មភាពបង្កើនចំណេះដឹងសហគមន៍ (community awareness activities) ប៉ុន្តែប្រាក់ដែលបានប្រើប្រាស់គឺអស់ត្រឹមកន្លះលានប៉ុណ្ណោះ។ ថវិកាដែលបានចំណាយដោយរដ្ឋសភាត្រូវបានយកទៅប្រើប្រាស់សម្រាប់បង្កើតជាឧបករណ៍ មធ្យោបាយ សម្រាប់កិច្ចទំនាក់ទំនងសាធារណៈ ក៏ដូចជាកិច្ចការបង្កើនចំណេះដឹងសហគមន៍។[16]

### ៤.២.១ អង្គភាព និងឧបករណ៍ប្រើប្រាស់ក្នុងកិច្ចទំនាក់ទំនងសាធារណៈ

នាយកដ្ឋានសេវាកម្មកិច្ចការសភា (the Department of Parliamentary Services) និងការិយាល័យអប់រំកិច្ចការសភា (the Parliamentary Education Office) ដើរតួនាទីសំខាន់ក្នុងកិច្ចការទំនាក់ទំនងសាធារណៈ។ សេវាកម្មមួយចំនួនរបស់នាយកដ្ឋានសេវាកម្មកិច្ចការសភា (the Department of Parliamentary Services) មានដូចជា ដំណើរការប៉ុស្តិ៍ទូរទស្សន៍ វិទ្យុទូរគមនាគមន៍ និងសេវាបណ្ណាល័យសភា។ ចំណែកឯការិយាល័យអប់រំកិច្ចការសភាវិញ (the Parliamentary Education Office) ជាអ្នកសម្របសម្រួលកម្មវិធីអប់រំទាក់ទងនឹងការងារសភា។[17] ខាងក្រោមនេះ គឺជាការបកស្រាយបន្ថែមទៅឧបករណ៍ដែលប្រើប្រាស់សម្រាប់កិច្ចការទំនាក់ទំនងសាធារណៈ៖

- ព័ត៌មានផ្សេងៗជាច្រើនស្តីពីការងារសភាត្រូវបានផ្ញើតាមរយៈអ៊ីម៉ែលរៀងរាល់ពីរសប្តាហ៍ម្តង។
- ប្រព័ន្ធផ្សព្វផ្សាយសង្គមជាច្រើន អាចជួយឲ្យមើលឃើញផ្ទាល់ពីដំណើរការសិក្ខាសាលា ទាក់ទាញឲ្យមានអ្នកចូលរួមកាន់តែច្រើន។
- កម្មវិធីមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីធ្វើការដោយផ្ទាល់ជាមួយសិស្ស និងសាធារណជន។ ឧទាហរណ៍ កម្មវិធី "ការប្រកួតប្រជែងការនិយាយបញ្ចេញគំនិតដំបូងរបស់ខ្ញុំ" (My First Speech Competition) លើកទឹកចិត្តឲ្យមានការចូលរួមរបស់យុវវ័យ។ លើសពីនេះទៀត មានកម្មវិធីដូចជា ការចុះកម្មសិក្សា និងកម្មវិធីផ្លាស់ប្តូរជាច្រើនដើម្បីជំរុញឲ្យសិស្សបានយល់ដឹងពីកិច្ចការសភា។
- ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិកមានដូចជា ធ្វីតធឺ (Twitter) ត្រូវបានប្រើប្រាស់ និងមានឈ្មោះថា @AboutTheHouse មានអ្នកគាំទ្រ (followers) ៣៧,០០០ នាក់។ ប្រព័ន្ធផ្សព្វផ្សាយសង្គមផ្តល់ការប្រាស្រ័យទាក់ទងទាន់ពេលវេលា ជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន។ ទំព័រហ្វេសប៊ុករបស់សភាមានអ្នកគាំទ្រ (followers) ៤,៦០០ នាក់ក្នុងឆ្នាំ ២០១៥-២០១៦។ ទំព័រហ្វេសប៊ុកនេះប្រកាសព័ត៌មានបែបពិពណ៌នាទៅលើការងារសភា និងគណៈកម្មការ។ អ៊ិនស្តាក្រាម (Instagram) គឺជាឧបករណ៍មួយផ្សេងទៀតដែលត្រូវបានប្រើប្រាស់

ដើម្បីចែកចាយព័ត៌មានអំពីសកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ពាក់ព័ន្ធទៅនឹងបញ្ហាបោះឆ្នោត។

- យូធូប (Youtube) មានអ្នកបង់ថ្លៃសេវាចំនួន ២,២៤០ នាក់។ យូធូបនេះដាក់បង្ហាញវីដេអូខ្លីៗដែលមានឈ្មោះថា "ពេលសម្រាប់សួរដេញដោល" និងមានភាពពេញនិយមខ្លាំង។
- សភាមានរៀបចំសិក្ខាសាលាទៅលើប្រធានបទសំខាន់ៗចំនួន ៤ ៖ "អំពីសភា" "អំពីថវិកា" "អំពីនីតិកម្ម" និង "អំពីគណៈកម្មការ"។ ក្នុងឆ្នាំ ២០១៥-២០១៦ មានសិក្ខាសាលាចំនួន ៥។ ហើយក្រៅពីនេះទៀត មានសិក្ខាសាលាទៅលើប្រធានបទជាច្រើនទៀត ដែលត្រូវបានរៀបចំដើម្បីបំពេញតាមតម្រូវការស្ថាប័នអង្គភាពផ្សេងៗ។ មតិឆ្លើយតបវិជ្ជមានចំពោះការរៀបចំសិក្ខាសាលាត្រូវបានកត់សម្គាល់តាមរយៈ ការវាយតម្លៃជាផ្លូវការ ។
- កាលពីឆ្នាំ ២០១៥-២០១៦ ក្នុងរយៈពេល ៧០ ថ្ងៃ មានអ្នកចូលទស្សនាសភាចំនួន ៥៥,៤៣៥ នាក់ ទាំងក្នុងថ្ងៃធ្វើការធម្មតា និងព្រឹត្តិការណ៍ផ្សេងៗ។
- ការិយាល័យអប់រំកិច្ចការសភា មានគោលដៅពង្រីកសកម្មភាពផ្សេងៗក្រៅស្ថាប័នទាក់ទងនឹងសិស្សានុសិស្ស។ គេហទំព័រការិយាល័យអប់រំកិច្ចការសភា (www.peo.gov.au) មានប្រសិទ្ធិភាពខ្ពស់ និងមានភាពល្បីល្បាញពាក់ព័ន្ធនឹងការផ្សព្វផ្សាយ ចែកចាយសម្ភារៈសិក្សា និងធនធានជាច្រើនទៅដល់គ្រូបង្រៀន និងសិស្សានុសិស្សនៅក្នុងប្រទេសទាំងមូល។ ក្នុងរយៈពេល ១ឆ្នាំ មានសិស្សចំនួន ៩០,០០០នាក់បានចូលរួមក្នុងកម្មវិធីការដើរតួជាអ្នកតំណាងរាស្ត្រ។ កម្មវិធីមួយមានឈ្មោះថា "ការប្រកួតប្រជែងការនិយាយបញ្ចេញគំនិតដំបូងរបស់ខ្ញុំ" (My First Speech Competition) តម្រូវឲ្យសិស្សសម្តែងធ្វើខ្លួនដូចនឹងសមាជិកសភាដែលទើបជាប់ឆ្នោត ហើយត្រូវសរសេរ និងធ្វើវីដេអូមានរយៈពេល ៣ នាទី ដែលនិយាយរ៉ែកញែកពីបញ្ហាផ្សេងៗទៅកាន់ប្រជាជន ឬសភា។ អ្នកដែលឈ្នះក្នុងការប្រកួតប្រជែង នឹងត្រូវអនុញ្ញាតឲ្យធ្វើបទបង្ហាញនៅចំពោះមុខប្រធានរដ្ឋសភា សមាជិករដ្ឋសភា និងព្រឹទ្ធសភា និងភ្ញៀវកិត្តិយសជាច្រើនទៀត។[16]
- ជាងនេះទៅទៀត សភាក៏មានប៉ុស្តិ៍ផ្ទាល់ខ្លួនមានឈ្មោះថា (ATH TV) ដែលអាចប្រើប្រាស់តាមរយៈអ៊ិនធឺណិត។ ប៉ុស្តិ៍នេះចាក់ផ្សាយព័ត៌មានដ៏សម្បូរបែបទាក់ទងនឹងកិច្ចដំណើរការសភា។ លើសពីនេះទៀត អ្នកទស្សនាអាចចែករំលែកវីដេអូផ្សេងៗទៅកាន់ ហ្វេសប៊ុក ធ្វីតធឺ លិងទីន (Facebook Twitter LinkedIn) និងបណ្តាញសង្គមជាច្រើនទៀត។[18]

### ៤.២.២ បទពិសោធន៍ល្អៗ

តាមរយៈការបកស្រាយខាងលើ អាចបង្ហាញបានថាសភាអូស្ត្រាលីបានដាក់បញ្ចូលនូវឧបករណ៍ឌីជីថលជាច្រើនដែលមានភាពស្រដៀង ឬអាចនិយាយបានថាមានភាពទូលំទូលាយជាងសភាសាធារណៈរដ្ឋកូរ៉េ។ សភាអូស្ត្រាលី មានអង្គភាពជាច្រើនដែលធ្វើការរួមគ្នាដើម្បីគាំទ្រដល់កិច្ច

ការទំនាក់ទំនងសាធារណៈ។ សភានេះក៏បានបង្កើតព្រឹត្តិការណ៍ជាច្រើន និងសកម្មភាពជាច្រើនដើម្បីធ្វើការផ្ទាល់ជាមួយសហគមន៍ និងយុវជន។ ជាងនេះទៀត អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺសភាបានព្យាយាមរកវិធីទាក់ទាញចំណាប់អារម្មណ៍សាធារណៈជនរួមទាំងកុមារផងដែរ។ ឧទាហរណ៍គឺ កម្មវិធីដែលមានឈ្មោះថា "ការប្រកួតប្រជែងការនិយាយបញ្ចេញគំនិតដំបូងរបស់ខ្ញុំ" ដែលបានផ្តល់ឱកាសដ៏ច្រើនសម្រាប់សិស្សានុសិស្សក្នុងការដើរតួសម្តែងធ្វើជាសមាជិកសភា និងព្យាយាមដោះស្រាយបញ្ហាផ្សេងៗរបស់សភា។

## ៤.៣ ស៊ុយអ៊ែត

សភាស៊ុយអ៊ែត (Riksdag) ត្រូវបានបង្កើតជាមួយនឹងការបោះឆ្នោតក្នុងឆ្នាំ ១៩២១ នៅពេលដែលប្រទេសនេះទទួលយករបបសភាប្រជាធិបតេយ្យពេញលេញ។ ក្នុងឆ្នាំ ១៩៧១ របបសភាមួយថ្នាក់ត្រូវបានកំណត់យក និងមានសមាជិក ៣៥០រូប។[19] បច្ចុប្បន្នសភានេះ មានសមាជិក ៣៤៩រូប គណបក្សចំនួន ៨ និងគណកម្មការចំនួន ១៥។[20] សភានេះមានមុខងារសំខាន់ៗដូចជា នីតិកម្ម អនុម័តច្បាប់ថវិការជាតិ ពិនិត្យតាមដានការងាររដ្ឋាភិបាល ធ្វើការជាមួយសហភាពអឺរ៉ុប និងធ្វើការពាក់ព័ន្ធនឹងគោលនយោបាយបរទេស។[21]

### ៤.៣.១ អង្គភាព និងឧបករណ៍ប្រើប្រាស់ក្នុងកិច្ចទំនាក់ទំនងសាធារណៈ

ការជំរុញបង្កើនចំណេះដឹង និង ការចូលរួមរបស់សាធារណៈគឺជាកម្មវត្ថុក្នុងកិច្ចការទំនាក់ទំនងសាធារណៈរបស់សភា។ ហេតុដូច្នេះ សភានេះបានបង្កើតអង្គភាព និងឧបករណ៍ជាច្រើនក្នុងកិច្ចការទំនាក់ទំនងសាធារណៈ។ ខាងក្រោមនេះជាអង្គភាពដែលពាក់ព័ន្ធ៖

- អង្គភាពបច្ចេកវិទ្យាព័ត៌មាវិទ្យា ធ្វើការពាក់ព័ន្ធនឹងការកសាងបណ្តាញបច្ចេកវិទ្យាព័ត៌មាវិទ្យា និងផ្តល់សេវាផ្សេងៗទាក់ទងនឹងវិស័យនេះ។
- អង្គភាពទំនាក់ទំនងជំរុញឲ្យមាន ការផ្សព្វផ្សាយ ភាពបើកចំហ ការចែករំលែកព័ត៌មានសភា និងការរៀបចំបង្កើតឧបករណ៍សម្ភារៈដែលអាចចែករំលែកជាមួយប្រជាជន។
- នាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយ ទំនាក់ទំនង និងអភិវឌ្ឍប្រព័ន្ធឌីជីថល (the Department of Media, Communications and Digital Development) ទទួលខុសត្រូវការងារប្រព័ន្ធផ្សព្វផ្សាយដែលទាក់ទងនឹងគេហទំព័រសភា (www.riksdagen.se) និង euupplysningen.se ពាក់ព័ន្ធនឹងប្រភពទិន្នន័យរបស់សភា និងការផ្តល់ព័ត៌មានទៅឲ្យសាធារណៈ។
- នាយកដ្ឋានទស្សនកិច្ច អប់រំ និងព្រឹត្តិការណ៍ (Department of Visits, Education and Events) ផ្តល់ការណែនាំ និងសម្ភារៈសំខាន់ៗទៅឲ្យអ្នកមកទស្សនា ជាពិសេសគឺសិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។

- បណ្ណាល័យសភា (Riksdag Library) មានធនធានសម្ភារៈជាច្រើនសម្រាប់ការងារច្បាប់ វិទ្យាសាស្ត្រនយោបាយ ការងារសភា និងបើកទូលាយសម្រាប់សាធារណៈជន។[22]

ឧបករណ៍សម្រាប់ការងារទំនាក់ទំនងមានដូចខាងក្រោម៖

- សេវាការចាក់ផ្សាយតាមអ៊ីនធឺណិត ត្រូវបានប្រើប្រាស់សម្រាប់ផ្សាយបន្តផ្ទាល់កិច្ចពិភាក្សា និងព្រឹត្តិការណ៍របស់សភា។ ក្រុមហ៊ុនឯកជនត្រូវបានអនុញ្ញាតឲ្យធ្វើការភ្ជាប់ និងផ្សព្វផ្សាយព្រឹត្តិការណ៍របស់សភា។
- សេវាព័ត៌មានផ្សេងៗរបស់សភា ផ្តល់ចម្លើយតាមទូរសព្ទ និងអ៊ីម៉ែល (riksdaginformation@riksdagen.se)។
- នាយកដ្ឋានសេវា "អ្នកគាំទ្រ និង ការបង់ប្រាក់" (Follow and Subscribe department) ផ្តល់សេវាសំខាន់ចំនួន ៤ ជាមួយនឹងការបង់ប្រាក់៖ ១/កម្មវិធី RSS សម្រាប់ប្រើប្រាស់ជាមួយកុំព្យូទ័រ ដែលធ្វើឲ្យអ្នកប្រើប្រាស់មិនចាំបាច់ចូលទៅកាន់គេហទំព័ររបស់សភា ២/ធ្វិតធឺ (@Sverigesriksdag) ៣/ទិន្នន័យចំហរបស់សភា (riksdagsinformation@riksdagen.se) ៤/ប្លុកសម្រាប់ការអភិវឌ្ឍ (development blog) (មតិយោបល់ និងទស្សនៈផ្សេងៗអាចត្រូវផ្ញើមក)។
- សេវាប្រព័ន្ធផ្សព្វផ្សាយផ្តល់ឲ្យអ្នកសារព័ត៌មាន និងអ្នកថតរូបដែលទទួលបានការទទួលស្គាល់ជាផ្លូវការពីសភា នូវបន្ទប់ពិសេសសម្រាប់ការប្រមូលព័ត៌មាន និងធ្វើកិច្ចពិភាក្សាជាមួយសមាគមអ្នកកាសែតរបស់សភា។[23]

### ៤.៣.២ បទពិសោធន៍ល្អៗ

វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់កិច្ចទំនាក់ទំនងសាធារណៈនៃសភាស៊ុយអ៊ែត មិនមានភាពខុសគ្នាខ្លាំងពីសភាពីរផ្សេងទៀតទេ។ សភាស៊ុយអ៊ែត មានប៉ុស្តិ៍ទូរទស្សន៍ នាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង អង្គភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា នាយកដ្ឋានទស្សនកិច្ច និងបណ្ណាល័យដែលសហការគ្នាក្នុងការងារចែករំលែកព័ត៌មានទៅកាន់សាធារណជន។ គួរឲ្យចាប់អារម្មណ៍សភាស៊ុយអ៊ែត បានសង្កត់ធ្ងន់លើការកសាងទំនាក់ទំនងល្អជាមួយប្រព័ន្ធផ្សព្វផ្សាយនៅខាងក្រៅ។ មានសមាគមសម្រាប់អ្នកកាសែតមួយ នៅក្នុងបរិវេណសភា ប៉ុន្តែអ្នកសារព័ត៌មាន អ្នកថតរូប និងអ្នកកាសែតត្រូវមានការទទួលស្គាល់ជាផ្លូវការពីសភាដើម្បីចូលយកព័ត៌មានក្នុងសភា។ អ្នកយកព័ត៌មានទាំងអស់ត្រូវបានផ្តល់នូវបន្ទប់ពិសេសដែលពួកគេអាចមើលកិច្ចប្រជុំ និងពិភាក្សាជាមួយសមាគម។

## ៥. សេចក្តីសន្និដ្ឋាន

នៅក្នុងសង្គមប្រជាធិបតេយ្យ សភាត្រូវបានចាត់ទុកថាជាសរីរាង្គដ៏សំខាន់ដែលតំណាងឲ្យពលរដ្ឋចំពោះបញ្ហាផ្សេងៗ។ នេះមានន័យថាសភាត្រូវការបង្កើតនូវវិធីសាស្ត្រដែលជំរុញឲ្យមាន

ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងសភា។ ទំនាក់ទំនងសាធារណៈគឺជាមធ្យោបាយដ៏សំខាន់សម្រាប់ទំនាក់ទំនង។

តាមរយៈការពិនិត្យអត្ថបទនេះឡើងវិញ យើងអាចមើលឃើញនូវឧបករណ៍ និងវិធីសាស្រ្តជាច្រើនដែលប្រើប្រាស់ដោយសភាសម្រាប់កិច្ចទំនាក់ទំនងសាធារណៈ និងជំរុញបង្កើតការយល់ដឹងសម្រាប់ប្រជាពលរដ្ឋមានដូចជា ការបោះពុម្ពផ្សាយរបាយការណ៍កិច្ចពិភាក្សា ការផ្សព្វផ្សាយព័ត៌មាន ការទស្សនារបស់សាធារណៈ ការភ្ជាប់ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ សកម្មភាពផ្សេងៗក្រៅស្ថាប័ន និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍទំនាក់ទំនងសាធារណៈត្រូវបានរារាំងដោយបញ្ហាប្រឈមជាច្រើន។ បញ្ហាទាំងនេះទាក់ទងទៅនឹងចំណាប់អារម្មណ៍ និងផលប្រយោជន៍របស់អាជីវកម្មក្នុងការផ្សព្វផ្សាយព័ត៌មានសភាតាមទូរទស្សន៍ កម្រិតនៃការយល់ដឹងទាក់ទងនឹងសារៈសំខាន់នៃកិច្ចការទំនាក់ទំនងសាធារណៈ កង្វះអ្នកឯកទេសក្នុងវិស័យនេះ របាំងទាក់ទងនឹងការប្រើប្រាស់ភាសា កង្វះចំណេះដឹងក្នុងការប្រើបច្ចេកវិទ្យា កង្វះភាពជាអ្នកដឹកនាំ និងការដឹកនាំសភា។

តាមរយៈករណីសិក្សានៃសភាទាំង ៣ បានបង្ហាញថានៅពេលទំនាក់ទំនងសាធារណៈដំណើរការល្អ ប្រជាពលរដ្ឋអាចទទួលដំណឹងអំពីសកម្មភាពរបស់សភា ដូច្នេះទំនាក់ទំនងរវាងសភា និងប្រជាពលរដ្ឋត្រូវបានបើកចំហ។ សភាទាំងបីមានបណ្តាញទូរទស្សន៍ដែលអាចផ្តល់ព័ត៌មាន ការប្រព្រឹត្តិទៅនៃការធ្វើច្បាប់ និងបញ្ហាផ្សេងៗទាន់ពេលវេលា។ ទន្ទឹមនឹងភាពជឿនលឿនបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីទូរស័ព្ទជាច្រើនត្រូវបានបង្កើតឡើង។ គេហទំព័ររបស់សភាទាំងបីមានលក្ខណៈទូលំទូលាយ និងដាក់បញ្ចូលនូវការតភ្ជាប់ និងព័ត៌មានសំខាន់ៗ។ គួរឲ្យកត់សម្គាល់បំផុត គឺការិយាល័យអប់រំ បណ្ណាល័យ និងនាយកដ្ឋានដែលធ្វើការទាក់ទងនឹងការចូលទស្សនា ពិតជាបានជួយជំរុញឲ្យសាធារណៈជនមានចំណេះដឹង និងកាន់តែមានភាពជិតស្និតជាមួយសភារបស់ពួកគេ។

ជាមួយនឹងការអនុវត្តល្អៗរបស់រដ្ឋសភាទាំងបីនេះ មានមេរៀនសំខាន់ៗដែលអាចយកមកពិចារណា។ ទីមួយ សភាទាំងនេះបានចាប់យកប្រយោជន៍យ៉ាងច្រើនពីការប្រើប្រាស់បច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាព័ត៌មានវិទ្យា។ មានការប្រើប្រាស់ឧបករណ៍ឌីជីថលជាច្រើនដូចជាកម្មវិធីទូរស័ព្ទ និងគេហទំព័រ ដែលផ្តល់នូវព័ត៌មាន កិច្ចទំនាក់ទំនង និងការតភ្ជាប់រវាងសភា និងសាធារណជន។ ទីពីរ សភាទាំងនេះត្រូវបំពាក់ជាមួយប៉ុស្តិ៍ទូរទស្សន៍ផ្ទាល់របស់ពួកគេ ឬតាមរយៈបណ្តាញឯកជន និងផ្សាយបន្តផ្ទាល់ពីសកម្មភាពសភា។ ចុងក្រោយ ជាកត្តាដ៏មានតម្លៃដែលសភាបានបញ្ចូលកម្មវិធីអប់រំសម្រាប់សិស្សនិស្សិតដែលនឹងជួយឲ្យពួកគេទទួលចំណេះដឹងពីដំណើរការសភា។

# ឯកសារយោង


1. INTER-PARLIAMENTARY UNION (2006). The Challenge of broadcasting parliamentary proceedings. Switzerland.
2. CREATIVE COMMONS (2012). Public Relations v 1.0.
3. SRIRAMESH KRISHNAMURTHY (2009). Globlisation and public relations: An overview looking into the future. Massey University.
4. INTER-PARLIAMENTARY UNION (2016). World e-Parliament Index 2016.
5. ASSOCIATION OF SECRETARIES GENERAL OF PARLIAMENTS (1986). Parliament and Public Relations Voting Methods Information Given to New Members of Parliament Geneva: Inter-Parliamentary Union.
6. INTER-PARLIAMENTARY UNION (2016). World e-Parliament Report 2016. France.
7. INTER-PARLIAMENTARY UNION (2007). The Challeng of Broodadcasting Parliamentary Proceedings. Geneva.
8. JOSEPH.A (2017). 7 Problems Facing Public Relations (Practice in Africa).
9. PUBLIC RELATIONS PLANNING OFFICE OF THE NATIONAL ASSEMBLY SECRETARIAT (2012). Leaflet of the National Assembly of the Republic of Korea. The Republic of Korea.
10. CHANG-HEE. K (2012). Building and Advanced National Assembly on the Basis of Dialogue and Comprise. The Republic of Korea: The Parliament of the Republic of Korea.
11. HALFON.R (2015). Citizen Engagement through ICT. United Kingdom.
12. NATIONAL ASSEMBLY OF THE REPUBLIC OF KOREA (2014). World e-Parliament Conference 2014.
13. SECRETARIAT OF THE NATIONAL ASSEMBLY OF THE REPUBLIC OF KOREA. (2012). *Parliamentary Education* [Online]. Available: http://korea.assembly.go.kr/secretary/over_01_02_03.jsp.
14. AUSTRALIA, H. O. R. O. (2017). *House of Representatives* [Online]. Available: http://www.aph.gov.au/About_Parliament/House_of_Representatives.
15. HOUSE OF REPRESENTATIVES OF AUSTRALIA. (2017). *About the House of Representatives* [Online]. Available: http://www.aph.gov.au/About_Parliament/House_of_Representatives/About_the_House_of_Representatives.
16. DEPARTMENT OF THE HOUSE OF REPRESENTATIVES (2015-2016). Annual Report. Australia.
17. PARLIAMENT OF AUSTRALIA. (2017). *Parliamentary Departments* [Online]. Available: http://www.aph.gov.au/About_Parliament/Parliamentary_Departments.
18. PARLIAMENT OF AUSTRALIA (2017). About the House TV.
19. PARLIAMENT OF SWEDEN. (2017). *The History of the Riksdag* [Online]. Available: http://www.riksdagen.se/en/how-the-riksdag-works/democracy/the-history-of-the-riksdag/.
20. PARLIAMENT OF SWEDEN. (2017). *Riksdag basics* [Online]. Available: http://www.riksdagen.se/en/.
21. PARLIAMENT OF SWEDEN. (2017). *What does the Riksdag do?* [Online]. Available: http://www.riksdagen.se/en/how-the-riksdag-works/what-does-the-riksdag-do/.
22. PARLIAMENT OF SWEDEN. (2017). *Organization* [Online]. Available: http://www.riksdagen.se/en/how-the-riksdag-works/the-riksdag-administration/organisation/.
23. PARLIAMENT OF SWEDEN. (2017). Available: http://www.riksdagen.se/en/.